**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**-សាលក្រមព្រហ្មទណ្ឌ**
**មុនអន្តសេចក្តី**
លេខ: ៦៨ "គ១ក្រ១០"
ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០២២
**-សំណុំរឿងព្រហ្មទណ្ឌ**
លេខ: ៩០០
ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២
**-សំណុំរឿងស៊ើបសួរ**
លេខ: ៦៨០
ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២២
**-សំណុំរឿងជំនុំជម្រះ**
លេខ: ១៧៤២
ចុះថ្ងៃទី ខែ ឧសភា ឆ្នាំ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២ វេលាម៉ោង ០២ និង ០០ នាទី រសៀល នៅសាលសវនាការទី ៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា។
-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា។
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា។

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

### មេធាវីការពារឱ្យជនជាប់ចោទ

-លោក [redacted] និងលោក [redacted]។

ដើម្បីជំនុំជម្រះលើ **សំណុំរឿងព្រហ្មទណ្ឌលេខ ៩០០ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២** ដែលមានពាក្យស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] **សីម៉ា**។

- ជនជាប់ចោទឈ្មោះ [redacted] **សីម៉ា** ភេទស្រី អាយុ ១៧ឆ្នាំ (កើតឆ្នាំ ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ សង្កា[redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ បន្ទប់ជួលគ្មានលេខ ផ្លូវរថភ្លើង ក្រុមទី ៦២ ភូមិទី ១៦ សង្កាត់ទឹកល្អក់ទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] ឡុង "រស់" ម្ដាយឈ្មោះ[redacted] "ស្លាប់" នៅលីវ ជាទីតិជន ទោសពីមុន គ្មាន។ (ក្នុងឃុំ - PJ)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៤៨៨ "ឡ" ដ.ឃ.ដ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២២។

ជាប់ចោទពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវរថភ្លើង ក្រុមទី ៦២ ភូមិទី ១៦ សង្កាត់ទឹកល្អក់ទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ **មាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន**។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ២០ និង ៣០នាទី កម្លាំងផ្នែកប្រឆាំងបទល្មើសគ្រឿងញៀននៃអធិការដ្ឋាននគរបាលខណ្ឌទួលគោក ស្រាវជ្រាវ និងល្បាតដល់ចំណុច ផ្លូវរថភ្លើង ក្រុមទី ៦២ ភូមិទី ១៦ សង្កាត់ទឹកល្អក់ទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឃើញជនជាប់ចោទឈ្មោះ [redacted] សីម៉ា ភេទស្រី កំពុងដើរ ដោយមានការសង្ស័យ កម្លាំងសមត្ថកិច្ចបានឃាត់ត្រួតពិនិត្យ និងបានឆែកឆេររកឃើញក្រាមពណ៌ សថ្លា ចំនួន ០២ កញ្ចប់ (គេស្គាល់បឋមជាប្រភេទមេតំហ្វេតាមីន) ដែលជនជាប់ចោទបានលាក់ទុកក្នុងចង្កេះខោ។ ក្រោយពីបានសាកសួរជនជាប់ចោទឈ្មោះ [redacted] សីម៉ា បានឆ្លើយបញ្ជាក់ថា ថ្នាំញៀននេះបានទិញពីបុរសមិនស្គាល់ឈ្មោះនៅចំណុច ផ្លូវរថភ្លើង ក្រុមទី ៦២ ភូមិទី ១៦ សង្កាត់ទឹក

ល្អក់ទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ សមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សីម៉ា និងកសាងសំណុំរឿង រួមទាំងវត្ថុតាងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ របាយការណ៍សំយោគលេខ ០២៣ រ.ប.ក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៦៧៣ អ.យ.ថ** ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ **១៤៥៧ អ.យ.ថ** ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **១៩៤៨ "ឡ" ដ.ដ** ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ពាក្យស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សីម៉ា។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] **សីម៉ា** បានឆ្លើយថា៖ ខ្ញុំបានដឹងកំហុស ហើយខ្ញុំពិតជាមានការរាងចាលមិនហ៊ានប្រព្រឹត្តម្ដងទៀតឡើយ ខ្ញុំសន្យាថានឹងចេញទៅរស់នៅធ្វើជាពលរដ្ឋល្អវិញ រស់នៅជុំគ្រួសារ ជួយការងារផ្ទះ មិនរឹងរូស និងធ្វើតាមតែចិត្តខ្លួនឯងទៀតទេ។ ខ្ញុំគ្រាន់តែជាជនរងគ្រោះនៃការប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ មិនមានបំណងទុច្ចរិតយកទៅលក់ដូរ ឬរក្សាទុកផ្ដល់ឱ្យអ្នកណាឡើយ។ ខ្ញុំមិនធ្លាប់ប្រព្រឹត្តបទល្មើសណាមួយពីមុនទេ ហើយករណីនេះជាលើកដំបូងរបស់ខ្ញុំ តែបន្ទាប់ពីខ្ញុំត្រូវឃុំខ្លួនក្នុងពន្ធនាគាររួចមក គឺបានធ្វើឱ្យខ្ញុំរាងចាល និងកែប្រែខ្លួន។ ខ្ញុំសន្យាថានឹងរកការងារសុច្ចរិតត្រឹមត្រូវ ធ្វើជាប្រជាពលរដ្ឋល្អក្នុងសង្គមឡើងវិញ និងមិនទៅពាក់ព័ន្ធជាមួយគ្រឿងញៀនទៀតទេ។ ខ្ញុំសន្យាថានឹងចូលខ្លួនតាមការកោះហៅរបស់តុលាការគ្រប់នីតិវិធី និងគោរពតាមគ្រប់លក្ខខណ្ឌដែលតុលាការបានកំណត់ទាំងអស់ដោយមិនរត់គេចទៅណាឡើយ។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

**តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖** ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងរួចមក តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សីម៉ា** ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ បានសុំនៅក្រៅឃុំបណ្ដោះអាសន្នដោយហេតុថា ខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង និងធានានឹងកែប្រែខ្លួនឡើងវិញ ហើយមិនមានមូលហេតុអ្វីផ្សេងទៀតឡើយ។ ដូច្នេះ សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

**មេធាវីឈ្មោះ** [redacted] **បានធ្វើសេចក្ដីសន្និដ្ឋានថា៖** នៅក្នុងរឿងនេះ កូនក្ដីខ្លួនសុំនៅក្រៅឃុំបណ្ដោះអាសន្ន ដោយហេតុថា កូនក្ដីខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកទី ១ ហើយមានការដឹងកំហុសច្បាស់លាស់បន្ទាប់ពីជាប់ពន្ធនាគារ ហើយមានបំណងកែប្រែខ្លួនជាមនុស្សល្អឡើងវិញនៅក្នុងសង្គម។ លើសពីនេះ កូនក្ដីខ្លួនបានធានាអះអាងចំពោះមុខតុលាការថា នឹងចូលគ្រប់នីតិវិធីរាល់ពេលដែលតុលាការធ្វើការកោះហៅមកបំភ្លឺនូវករណីទាំងអស់ចំពោះមុខតុលាការ និងសន្យាមិនបង្កឱ្យមានភាពច្របូកច្របល់ក្នុងសង្គមឡើយ។ សំណូមពរឱ្យតុលាការសម្រេចឱ្យកូនក្ដីខ្លួនបាននៅក្រៅឃុំបណ្ដោះអាសន្ន។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ ✓

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

- តាមពាក្យស្នើសុំនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សីម៉ា ពិតជាបានស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នប្រាកដមែន។

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សីម៉ា ដែលបានឆ្លើយនាពេលសវនាការ ឃើញថា ជនជាប់ចោទរូបនេះពិតជាបានស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នប្រាកដមែន ប៉ុន្តែជនជាប់ចោទពុំមានហេតុផលអ្វីផ្សេងក្រៅពីការអះអាងថា ខ្លួនដឹងកំហុស និងសន្យាថានឹងកែប្រែខ្លួនឱ្យល្អឡើងវិញនៅក្នុងសង្គម។

- មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនសុំនៅក្រៅឃុំបណ្តោះអាសន្ន ដោយហេតុថា កូនក្តីខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកទី ១ ហើយមានការដឹងកំហុសច្បាស់លាស់បន្ទាប់ពីជាប់ពន្ធនាគារ ហើយមានបំណងកែប្រែខ្លួនជាមនុស្សល្អឡើងវិញនៅក្នុងសង្គម។ លើសពីនេះ កូនក្តីខ្លួនបានធានាអះអាងចំពោះមុខតុលាការថា នឹងចូលគ្រប់នីតិវិធីរាល់ពេលដែលតុលាការធ្វើការកោះហៅមកបំភ្លឺនូវករណីទាំងអស់ចំពោះមុខតុលាការ និងសន្យាមិនបង្កឱ្យមានភាពច្របូកច្របល់ក្នុងសង្គមឡើយ។ សំណូមពរឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំ បណ្តោះអាសន្ន។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ **សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។**

តុលាការយល់ឃើញថា៖

- ជនជាប់ចោទឈ្មោះ [redacted] សីម៉ា ត្រូវបានចោទប្រកាន់ពីបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។
- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។
- ដើម្បីធានារក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។
- បទល្មើស គឺបង្កភាពអសន្តិសុខយ៉ាងខ្លាំងដល់សង្គម។

## ហេតុដូច្នេះសម្រេច

- មិនអនុញ្ញាតឱ្យនៅក្រៅឃុំបណ្តោះអាសន្នលើជនជាប់ចោទឈ្មោះ [redacted] សីម៉ា ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវរថភ្លើង ក្រុមទី ៦២ ភូមិទី ១៦ សង្កាត់ទឹកល្អក់ទី ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ **មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សីម៉ា និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០២២។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ចន្ទ ៦ កើត ខែ អាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner